ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧៦ . សសរ

# សេចក្តីសម្រេច
## ស្តីពី
## ឯកសារណែនាំសម្រាប់កិច្ចប្រជុំពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាលនិងអង្គការមិនមែនរដ្ឋាភិបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១៤៩ អនក្រ.បក ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- តាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធានទី១នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

## សម្រេច

**ប្រការ ១ :-**

រៀបចំឱ្យមានកិច្ចប្រជុំពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាលនិងអង្គការមិនមែនរដ្ឋាភិបាល ជារៀងរាល់ឆ្នាំ នាត្រីមាសទីមួយនៃឆ្នាំ ឬតាមពេលវេលាសមស្របរបស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ។ ការរៀបចំនិងការប្រព្រឹត្តទៅនៃកិច្ចប្រជុំប្រចាំឆ្នាំនេះ ត្រូវអនុវត្តតាមឯកសារណែនាំ ដូចមានភ្ជាប់ជាមួយនឹងសេចក្តីសម្រេចនេះ ។

**ប្រការ ២ :-**

ប្រគល់ភារកិច្ចជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានទី១នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សម្រាប់សម្របសម្រួលកិច្ចប្រជុំពិគ្រោះយោបល់ប្រចាំឆ្នាំនេះ ។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់** ត្រូវរាយការណ៍ជាបន្តបន្ទាប់ជូន **សម្តេចតេជោ នាយករដ្ឋមន្ត្រី** អំពីវឌ្ឍនភាពនៃការរៀបចំនិងឯកសារចាំបាច់នានា សម្រាប់ស្នើជូន **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ពិនិត្យ និងផ្តល់អនុសាសន៍ ។

**ប្រការ ៣ :-**

គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ.ជ.នា/ក.អ.ក) ក្រោមការគ្រប់គ្រងរបស់ឯកឧត្តម **ឈៀង យ៉ាណារ៉ា** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ត្រូវបំពេញតួនាទីជាលេខាធិការដ្ឋានសម្រាប់រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ប្រចាំឆ្នាំ ។ ក្នុងការរៀបចំ លេខាធិការដ្ឋានត្រូវសហការជាមួយនឹងបណ្តាក្រសួងនិងស្ថាប័នពាក់ព័ន្ធ និងក្រុមសម្របសម្រួលរបស់អង្គការមិនមែនរដ្ឋាភិបាល ហើយត្រូវរាយការណ៍អំពីវឌ្ឍនភាពការងារ ជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី **គាត ឈន់** ។

**ប្រការ ៤ :-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីនិងរដ្ឋលេខាធិការគ្រប់ក្រសួងនិងស្ថាប័នពាក់ព័ន្ធ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងសាមីខ្លួន ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះ ។

**ប្រការ ៥ :-**

សេចក្តីសម្រេចនេះមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០១២

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យ **សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
- ដូចប្រការ៤ «ដើម្បីអនុវត្ត»
- ឯកសារ-កាលប្បវត្តិ

**សម្តេច អគ្គមហាសេនាបតី តេជោ ហ៊ុន សែន**